ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន

Ministry of Environment

លេខ: ៥៣៣ ស.ន.ណ ប.ស្ល

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ២០១៣

# សេចក្តីជូនដំណឹង

## ស្តីពី

## វេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ

### ក្រោមប្រធានបទ

*"ធ្វើសកម្មភាពឆ្ពោះទៅការអភិវឌ្ឍដោយធន់ទៅនឹងការប្រែប្រួលអាកាសធាតុ"*

គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ មានកិត្តិយសសូមជម្រាបជូនសាធារណជន បណ្តាញសារព័ត៌មានជាតិ និងអន្តរជាតិទាំងអស់ឱ្យបានជ្រាបថា រាជរដ្ឋាភិបាលកម្ពុជា បានឯកភាពជាគោលការណ៍ឱ្យក្រសួងបរិស្ថាន ក្រោមកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ រៀបចំ **វេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី០៥ ដល់ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៣** នៅរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា។

វេទិកាជាតិនេះ មានគោលបំណងផ្តល់ឱកាសសម្រាប់ពិភាក្សា ចែករំលែកព័ត៌មាន ពាក់ព័ន្ធនឹងប្រធានបទប្រែប្រួលអាកាសធាតុ សំដៅពង្រឹងវិធានឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ជាពិសេសផ្តោតលើការផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់បណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធ និងលទ្ធផលដែលសម្រេចបាន សំដៅធានានូវកិច្ចសហប្រតិបត្តិការ និងភាពបន្សុីគ្នា រវាងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ជាមួយបណ្តាគំនិតផ្តួចផ្តើមប្រែប្រួលអាកាសធាតុនានា។

ពិធីបើកវេទិកាជាតិនេះ នឹងប្រព្រឹត្តទៅនៅព្រឹកថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅអគារសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន និងបណ្តាញសារព័ត៌មានទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

សម្រាប់ព័ត៌មានលម្អិត សូមទាក់ទងនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន អគារលេខ៤៨ មហាវិថីព្រះសីហនុ ជាន់ទី២ បន្ទប់លេខ ៣០៣B រាជធានីភ្នំពេញ។ ទូរស័ព្ទ/ទូរសារៈ (+៨៥៥)២៣ ២១៨ ៣៧០ គេហទំព័រៈ www.camclimate.org.kh


មន្ត្រីទំនាក់ទំនង ៖

- លោក **ម៉ា ច័ន្ទសេទ្ធា** អនុប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃក្រសួងបរិស្ថាន
  សារអេឡិចត្រូនិចៈ machansethea@yahoo.com
  លេខទូរស័ព្ទៈ(+៨៥៥)៧៧ ៧៣ ០៤ ០៥
- លោកស្រី **នៅ រស្មី** មន្ត្រីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា
  សារអេឡិចត្រូនិចៈ reaksmey.neou@camclimate.org.kh
  លេខទូរស័ព្ទៈ(+៨៥៥) ៧៧ ៥៣ ៥៣ ៩២


CAMBODIA CLIMATE CHANGE ALLIANCE

Implemented by: Ministry of Environment

Supported by: European Union, UNDP, Danida, SWEDEN

# KINGDOM OF CAMBODIA
NATION-RELIGION-KING

~~~~~~~~~~

COUNCIL OF MINISTERS
Ministry of Environment
~~~~~~

No :.....533..............MoE

Phnom Penh......15.....October,..2013..

## Announcement

### Third National Forum on Climate Change

*"Taking Action for Sustainable Development in the Changing Climate"*

The National Climate Change Committee of the Royal Government of Cambodia has the honor to inform the public, national and international press that the Royal Government of Cambodia has agreed in principle to authorize the Ministry of Environment, in cooperation with Development Partners, to organize **the Third National Forum on Climate Change** on **05th- 07th November 2013** in Phnom Penh, Cambodia.

***The forum aims*** to provide a platform where various discussions on climate change can be consolidated, information shared and climate change responses enhanced, particularly focusing on sharing various key stakeholder's respective climate change strategic plans and their outcomes, creating an opportunity for synergy and alignment between the Government efforts with other key climate change initiatives.

***The opening ceremony*** will be organized on 05th November 2013 at the Peace Building, Office of the Council of Ministers. The ceremony will be presided over by **Samdech Akka Moha Sena Padei Techo HUN SEN, Prime Minister of Cambodia.**

Kindly be informed that attendance at this Forum will be by invitation only.

For more information, please contact the **Climate Change Department** of Ministry of Environment, #48 Preah Sihanouk Blvd, 2nd floor, Room 303B, Phnom Penh, Cambodia. Tel/Fax: (+855)23 218 370; Website: www.camclimate.org.kh

**Contact persons:**

Mr. **Ma Chansethea**, Deputy Director of Climate Change Department, Ministry of Environment
E-mail: machansethea@yahoo.com

Tel: (+855)77 73 04 05

Mrs. **Neou Reaksmey**, Knowledge Management Assistant, Cambodian Climate Change Alliance
E-mail: reaksmey.neou@camclimate.org.kh

Tel: (+855)77 53 53 92

CAMBODIA CLIMATE CHANGE ALLIANCE
Implemented by: Ministry of Environment
Supported by: European Union, UNDP, Danida, SWEDEN